**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

លេខ :៣២៤/សស.គក
/១៥

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែឧសភា ឆ្នាំ ២០១៥

# សេចក្តីសម្រេច
## ស្តីពី
## តួនាទី ភារកិច្ច អង្គការចាត់តាំង និងរបៀបរបបធ្វើការ
## របស់គណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាល

**យោង៖** - ជំពូក VIII មាត្រាទី ២៣ នៃលក្ខន្តិកៈរបស់គណបក្ស ស្តីពីការទទួលស្គាល់តួនាទីរបស់អង្គការសង្គម

- សេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលលេខ ៨៧/១៥ សស.គក ចុះថ្ងៃទី១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ស្តីពីការបង្កើត និងតែងតាំងប្រធានគណៈចលនាមហាជន
- ស្មារតីនៃអង្គប្រជុំគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៥
- មតិឯកភាពរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល

## គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលសម្រេច

**ប្រការ១:** គណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាល មានតួនាទីជាស្ថាប័នជំនួយការឲ្យគណៈកម្មាធិការកណ្តាល ក្នុងការដឹកនាំ ណែនាំ តម្រង់ទិស និងសម្របសម្រួល ការងារចលនាមហាជនរបស់គណបក្សក្នុងស្រទាប់មហាជន យុវជន ស្ត្រី កម្មករ និយោជិត និងអង្គការសង្គមនានា។

**ប្រការ២:** គណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាលមានភារកិច្ច ៖

១- កំណត់គោលការណ៍ដឹកនាំ គ្រប់គ្រងការងារចលនាមហាជន នៅតាមគ្រប់បណ្តាមូលដ្ឋានដូចជាសហគមន៍ គ្រឹះស្ថានសាធារណៈ ឯកជន អង្គការ សមាគម និងសាសនានានា ក្នុងន័យក្តាប់ឲ្យបាននូវតម្រូវការ សំណូមពរ និងសតិអារម្មណ៍ ដើម្បីវិភាគចំណុចខ្លាំង ចំណុចខ្សោយ បញ្ហាប្រឈម និងកាលានុវត្តភាពរបស់គណបក្ស ដើម្បីកសាងនូវយន្តការដោះស្រាយសមស្របមួយសំដៅអនុវត្តឲ្យបានជោគជ័យនូវកម្មវិធីនយោបាយ និងគោលនយោបាយរបស់គណបក្ស ។

២- ស្រាវជ្រាវសភាពការណ៍សតិអារម្មណ៍ក្នុងស្រទាប់យុវជន ស្ត្រី កម្មករ និយោជិត និងគ្រប់មជ្ឈដ្ឋានមហាជន ដោយសហការជាមួយគណៈឃោសនាអប់រំ គណៈកម្មាធិការកណ្តាល ដើម្បីរៀបចំផែនការ កម្មវិធី ខ្លឹមសារអប់រំនយោបាយ បណ្តុះបណ្តាល និងបំពាក់បំប៉ន ហើយធ្វើសំណើជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលពិនិត្យ និងសម្រេច ។

៣- កសាងផែនការសកម្មភាពការងាររបស់គណៈចលនាមហាជន និងអនុម័តផែនការសកម្មភាពរបស់គណៈចលនានីមួយៗ ។

៤- តាមដាន ត្រួតពិនិត្យ ធ្វើការវាយតម្លៃការអនុវត្តតួនាទី ភារកិច្ចរបស់បណ្តាគណៈចលនាចំណុះ សំដៅកែលម្អ និងពង្រឹងឲ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព ។

៥- តាមដាន ស្វែងយល់វិភាគសកម្មភាព និងឧបាយកលរបស់មជ្ឈដ្ឋានអមិត្ត ដើម្បីមានវិធានការឆ្លើយតបជាក់ស្តែង ឲ្យបានសមស្រប ទាន់ពេលវេលាតាមគ្រប់មធ្យោបាយ ។

៦- កៀរគរប្រភពធនធានស្របច្បាប់ ដើម្បីជាមធ្យោបាយបំពេញភារកិច្ចប្រកបដោយប្រសិទ្ធភាព ។

៧- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ អំពីបច្ចុប្បន្នភាព និងវឌ្ឍនភាពរបស់គណៈចលនាមហាជន ជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ។

៨- បំពេញភារកិច្ចផ្សេងៗទៀត ដែលគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលប្រគល់ជូន ។

**ប្រការ៣:** គណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាល មានរចនាសម្ព័ន្ធដូចតទៅ៖

១- គណៈចលនាយុវជន មានតួនាទីជាសេនាធិការរបស់គណៈចលនាមហាជន ក្នុងការដឹកនាំ ណែនាំ តម្រង់ទិស សម្របសម្រួល តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តភារកិច្ចរបស់អង្គការចាត់តាំង យន្តការ និងក្រុមការងារទាំងអស់របស់គណបក្ស ដែលបំពេញការងារចលនាយុវជន ដើម្បីធានាបាននូវសុខដុមនីយកម្មការងារចលនាយុវជនក្រោមការដឹកនាំរួមរបស់គណបក្ស ។

២- គណៈចលនាស្ត្រី មានតួនាទីជាសេនាធិការរបស់គណៈចលនាមហាជន ក្នុងការដឹកនាំ ណែនាំ តម្រង់ទិស សម្របសម្រួល តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តភារកិច្ចរបស់អង្គការចាត់តាំង យន្តការ និងក្រុមការងារទាំងអស់របស់គណបក្ស ដែលបំពេញការងារចលនាស្ត្រី ដើម្បីធានាបាននូវសុខដុមនីយកម្មការងារចលនាស្ត្រីក្រោមការដឹកនាំរួមរបស់គណបក្ស ។

៣- គណៈចលនាសហជីព មានតួនាទីជាសេនាធិការរបស់គណៈចលនាមហាជន ក្នុងការដឹកនាំ ណែនាំ តម្រង់ទិស សម្របសម្រួល តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តភារកិច្ចរបស់អង្គការចាត់តាំង យន្តការ និងក្រុមការងារទាំងអស់របស់គណបក្ស ដែលបំពេញការងារក្នុងស្រទាប់កម្មករ និយោជិត និងនិយោជក ដើម្បីធានាបាននូវសុខដុមនីយកម្មការងារចលនាកម្មករ និយោជិតក្រោមការដឹកនាំរួមរបស់គណបក្ស ។

៤- គណៈចលនាអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍ មានតួនាទី ជាសេនាធិការរបស់គណៈចលនាមហាជន ក្នុងការតម្រង់ទិស សម្របសម្រួល ជួយឧបត្ថម្ភ និងសហការជាមួយសមាគម ដៃគូអភិវឌ្ឍន៍ និងក្រុមការងារនានា ដែលបំពេញការងារក្នុងស្រទាប់មហាជន ក្រៅពីចលនាយុវជន ស្ត្រី កម្មករ និងនិយោជិត ដើម្បីបំផុសចលនាប្រជាជន ការពារសមិទ្ធផលសង្គមជាតិ និងកសាងប្រទេសជាតិ ស្របតាមកម្មវិធីនយោបាយរបស់គណបក្ស ។

**ប្រការ៤**: គណៈចលនាមហាជន ធ្វើការតាមរបបសមូហភាពដឹកនាំ បុគ្គលទទួលខុសត្រូវ ដោយត្រូវប្រជុំសាមញ្ញ មួយខែម្តង ក្នុងករណីចាំបាច់ អាចកោះប្រជុំជាវិសាមញ្ញបាន ។

**ប្រការ៥**: គណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាល គណៈចលនានីមួយៗ និងអគ្គលេខាធិការដ្ឋានដឹកនាំដោយៈ

- ប្រធាន ១រូប
- អនុប្រធាន និងសមាជិកមួយចំនួនតាមការចាំបាច់ ។

**ប្រការ៦**: អគ្គលេខាធិការដ្ឋាន មានភារកិច្ចដូចខាងក្រោម ៖

- ទទួលពិនិត្យ និងចាត់ចែងនូវរាល់លិខិតចេញ-ចូល ដែលស្ថាប័នជុំវិញគណៈកម្មាធិការកណ្តាលផ្ញើជូនគណៈចលនាមហាជន ។
- បញ្ជូនគោលការណ៍ សេចក្តីសម្រេច សារាចរណែនាំ និងលិខិតស្នាមរដ្ឋបាលពាក់ព័ន្ធនានា របស់គណៈចលនាមហាជន ទៅបណ្តាអង្គភាពចំណុះគណៈចលនាមហាជន ។
- ទំនាក់ទំនង សហការ ពិនិត្យ ដោះស្រាយ ទទួល បញ្ជូន លិខិតស្នាមរដ្ឋបាល ឯកសារផ្សេងៗទៀត ពីគណៈចលនាមហាជន ទៅស្ថាប័នពាក់ព័ន្ធនានា ។
- រៀបចំកិច្ចប្រជុំ សិក្ខាសាលា សន្និបាត និងការងារពិធីការផ្សេងៗ របស់គណៈចលនាមហាជន ។
- គ្រប់គ្រងឯកសារ បុគ្គលិក ភស្តុភារ និងគណនេយ្យ របស់គណៈចលនាមហាជន ។
- ធ្វើការបូកសរុប វាយតម្លៃរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ របស់គណៈចលនានីមួយៗ ជូនគណៈចលនាមហាជន ។
- បំពេញភារកិច្ចផ្សេងៗទៀត ដែលគណៈចលនាមហាជនប្រគល់ជូន ។

**ប្រការ៧**: គណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាល ពិនិត្យការរៀបចំតួនាទី ភារកិច្ច រចនាសម្ព័ន្ធ និងសមាសភាព ដែលស្នើឡើងដោយគណៈចលនានីមួយៗ ហើយដាក់ជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលពិនិត្យ និងសម្រេច ។

**ប្រការ៨**: គណៈចលនាមហាជនរបស់គណបក្ស ត្រូវចាត់តាំងបង្កើត នៅថ្នាក់កណ្ដាល និងថ្នាក់រាជធានី ខេត្ត ។

គណៈចលនាមហាជនគណៈកម្មាធិការគណបក្សរាជធានី ខេត្ត មានប្រធានគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ជាប្រធាន និងមានអនុប្រធាន និងសមាជិកមួយចំនួនតាមការចាំបាច់ ។

ចំពោះថ្នាក់ក្រសួង ស្ថាប័ន ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវរៀបចំបែងចែកភារកិច្ចក្នុងគណៈកម្មាធិការគណបក្ស ដូចខាងក្រោម ៖

- ថ្នាក់ក្រសួង ស្ថាប័ន ក្រុង ស្រុក ខណ្ឌ មានអនុប្រធានគណៈកម្មាធិការគណបក្ស ០១រូប ទទួលបន្ទុក ។ គណៈកម្មាធិការគណបក្សអាចចាត់តាំងមន្ត្រីមួយចំនួនតាមការចាំបាច់ ជាជំនួយការការងារចលនាមហាជន ។

- ថ្នាក់ឃុំសង្កាត់ មានអនុប្រធានគណៈកម្មាធិការគណបក្ស ០១រូប ទទួលបន្ទុក ។

**ប្រការ៩**: ខុទ្ទកាល័យ គណៈចាត់តាំង គណៈចលនាមហាជននៃគណៈកម្មាធិការកណ្ដាល និងស្ថាប័នគណបក្សដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមសេចក្ដីសម្រេចនេះ ៕

ជ.គណៈអចិន្ត្រៃយ៍.ស.

ប្រធាន

ជា ស៊ីម

ចម្លងជូន ៖
- សមាជិកគណៈអចិន្ត្រៃយ៍ នៃគណៈកម្មាធិការកណ្ដាល
- ដូចប្រការ ៩
- ឯកសារ កាលប្បវត្តិ

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្ដាល

លេខ: ៧៩២/១០២៥ សស.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និងវឌ្ឍនភាពសង្គម

ថ្ងៃអង្គារ ១៤រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០២៥

# សេចក្តីសម្រេច
## ស្តីពីការកែសម្រួលខ្លឹមសារប្រការ ៨ នៃ សេចក្តីសម្រេចលេខ ៣២៧/១៥ សស.គក ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០១៥

**យោង** :
- សេចក្តីសម្រេចលេខ ៣២៧/១៥ សស.គក ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០១៥ ស្តីពីតួនាទី ភារកិច្ច អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាល
- សេចក្តីណែនាំបន្ថែមលេខ ០១/១៦ សណ.គក ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១៦ ស្តីពីការរៀបចំប្រធានគណៈចលនាមហាជន ប្រធានគណៈចលនាយុវជននៃគណបក្សរាជធានី ខេត្ត
- ស្មារតីអង្គប្រជុំគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល នាថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០២៥

## គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលសម្រេច

**ប្រការ ១**: កែសម្រួលខ្លឹមសារប្រការ ៨ នៃសេចក្តីសម្រេចលេខ ៣២៧/១៥ ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០១៥ ស្តីពីតួនាទី ភារកិច្ច អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាល មកជា៖

"**ប្រការ ៨**: គណៈចលនាមហាជនរបស់គណបក្ស ត្រូវបានចាត់តាំងបង្កើតនៅថ្នាក់កណ្តាល ថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ" ។

គណៈចលនាមហាជន និងគណៈចលនាយុវជនរបស់គណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានមន្ត្រីគណបក្សដែលជាអភិបាល ឬជាប្រធានគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាប្រធាន និងមានអនុប្រធាន និងសមាជិកមួយចំនួនតាមការចាំបាច់ ។

ថ្នាក់ក្រសួង ស្ថាប័ន ត្រូវបង្កើតក្រុមចលនាមហាជន និងមានប្រធាន ឬអនុប្រធានគណៈកម្មាធិការគណបក្ស ១រូប ទទួលបន្ទុក ។ គណៈកម្មាធិការគណបក្សអាចចាត់តាំងមន្ត្រីមួយចំនួនតាមការចាំបាច់ជាជំនួយការការងារចលនាមហាជន ។

គណៈកម្មាធិការគណបក្សមូលដ្ឋានចំណុះក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតក្រុមចលនាមហាជន និងមានប្រធាន ឬអនុប្រធានគណៈកម្មាធិការគណបក្ស ១រូប ទទួលបន្ទុក ។

ថ្នាក់ឃុំ សង្កាត់ ត្រូវមានមន្ត្រីគណបក្សដែលជាមេឃុំ ចៅសង្កាត់ ឬប្រធានគណៈកម្មាធិការគណបក្សទទួលបន្ទុក ។ គណៈកម្មាធិការគណបក្ស រួមជាមួយក្រុមការងារគណបក្សចុះមូលដ្ឋានរៀបចំបង្កើតក្រុមចលនាមហាជនឃុំ សង្កាត់ ។

**ប្រការ ២**: ខុទ្ទកាល័យ គណៈចាត់តាំង និងគណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាល និងស្ថាប័នគណបក្សដែលពាក់ព័ន្ធ មានភារកិច្ចចាត់តាំងអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ។

**ជ.គណៈអចិន្ត្រៃយ៍**
**ប្រធាន**

**ហ៊ុន សែន**